ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក នៃក្រសួងធនធានទឹក និងឧតុនិយម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

## ស ម្រេ ច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅបង្កើតនាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក ចំណុះអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស របស់ក្រសួងធនធានទឹក និងឧតុនិយម បំពេញបន្ថែមក្នុងវចនាសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធាន និងឧតុនិយម ។

**មាត្រា ២.-**

នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក មានភារកិច្ចដូចតទៅ :

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្ត លើប្រព័ន្ធធារាសាស្ត្រ ឱ្យមាននិរន្តរភាព ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សិក្សា ស្រាវជ្រាវ និងចងក្រងនូវព័ត៌មាន និងទិន្នន័យទាំងអស់របស់ប្រព័ន្ធធារាសាស្ត្រ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីកំណត់ និងបង្កើតឡើងនូវមូលដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រច្បាស់លាស់ បង្កលក្ខណៈងាយស្រួលដល់ការងារគ្រប់គ្រង និងកិច្ចអភិវឌ្ឍន៍បន្ត
- លើកទិសដៅ ផែនការរយៈពេលខ្លី មធ្យម និងវែង ក្នុងការគ្រប់គ្រងកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រទាំងអស់ ដើម្បីបម្រើដល់សេដ្ឋកិច្ចជាតិ និងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- គ្រប់គ្រង ត្រួតពិនិត្យនូវរាល់ការប្រើប្រាស់លើវិស័យប្រព័ន្ធធារាសាស្ត្រដោយផ្ទាល់និងប្រយោល ប្រកបដោយនិរន្តរភាព និងកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រោះមហន្តរាយដែលអាចកើតមានឡើងជាយថាហេតុ
- រៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ថែទាំ កិច្ចដំណើរការ និងការអភិវឌ្ឍបន្តលើប្រព័ន្ធធារាសាស្ត្រ ព្រមទាំងតាមដានលើការអនុវត្ត
- ផ្តល់ការគាំទ្រ និងការណែនាំបច្ចេកទេសជាចាំបាច់ដល់ឯកជន អង្គការវិជ្ជាជីវៈ សហគមន៍កសិករប្រើប្រាស់ទឹក និងប្រជាពលរដ្ឋទូទៅ ដែលមានការពាក់ព័ន្ធក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ឱ្យបានសមស្រប និងមាននិរន្តរភាព
- ពង្រីកការស្រាវជ្រាវ ការអនុវត្ត និងបញ្ចូលនូវបច្ចេកវិទ្យាទំនើបៗ លើការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងធ្វើការបណ្តុះបណ្តាល កែលំអ និងផ្សព្វផ្សាយ ដល់មន្ត្រីរាជការ និងសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក ក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីធានានិរន្តរភាពរបស់ប្រព័ន្ធធារាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

**មាត្រា ៣.-**

នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ នៃនាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ